# សេចក្តីថ្លែងការណ៍រួម

ភ្នំពេញ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥

## ការពង្រឹងសេរីភាពសារព័ត៌មានដើម្បីលើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ

រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ អ្នកសារព័ត៌មាន និងអ្នកធ្វើការខាងវិស័យប្រព័ន្ធផ្សព្វផ្សាយជាច្រើន នៅជុំវិញពិភពលោកត្រូវបានវាយប្រហារ ឃុំខ្លួន និងធ្វើឃាត ហើយរាល់ការបោះពុម្ពផ្សាយត្រូវបានត្រួតពិនិត្យយ៉ាងតឹងរឹង ឬ អាចប្រឈមនឹងការបិទទៀតផង។ ការរឹតត្បិតសេរីភាពសារព័ត៌មានបែបនេះ រារាំងដល់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពខាងការបញ្ចេញមតិ ដែលជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍន៍ក្នុងសង្គមប្រជាធិបតេយ្យ។

ទិវាសេរីភាពសារព័ត៌មានពិភពលោកថ្ងៃទី០៣ ខែឧសភា គឺជាការរំលឹកដល់រដ្ឋាភិបាល ស្ថាប័នសារព័ត៌មាន និងសង្គមស៊ីវិលការក្នុងធ្វើការរួមគ្នា ដើម្បីជម្នះនូវឧបសគ្គទាំងនោះ និងធ្វើយ៉ាងណាធានាឲ្យមានការការពារដល់វិស័យប្រព័ន្ធផ្សព្វផ្សាយចម្រុះ និងឯករាជ្យភាព។

នៅមុនទិវាសេរីភាពសារព័ត៌មានពិភពលោកនៅក្នុងឆ្នាំនេះ យើងជាក្រុមសង្គមស៊ីវិលមានរាយនាមដូចខាងក្រោមសូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជាជាពិសេសក្រសួងព័ត៌មាន ប្រព័ន្ធតុលាការ អង្គការដែលធ្វើការផ្នែកប្រព័ន្ធផ្សព្វផ្សាយ សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ទាំងអស់ ចាត់វិធានការដាក់លាក់ដូចខាងក្រោម ដើម្បីឲ្យអ្នកសារព័ត៌មានបំពេញការងាររបស់ខ្លួនប្រកបដោយជោគជ័យ ៖

- ក្រសួងព័ត៌មានគួរបង្កើតឱ្យមានអង្គភាពផ្តល់អាជ្ញាប័ណ្ណប្រកបដោយតម្លាភាព និងឯករាជ្យពេញលេញដើម្បីធានាថាការចេញអាជ្ញាប័ណ្ណផ្សព្វផ្សាយមានភាពស្មើគ្នា ដើម្បីលើកកម្ពស់សម្លេង និងមតិយោបល់ចម្រុះតាមរយៈរលកជាតុអាកាស។ ក្រសួងគួរតែចេញផ្សាយជាបន្ទាន់នូវបញ្ជីឈ្មោះរបស់ម្ចាស់ស្ថានីយ ប្រេកង់វិទ្យុ និងទូរទស្សន៍ដែលមានស្រាប់។
- ប្រព័ន្ធតុលាការ និងតុលាការត្រូវចាត់វិធានការ ដើម្បីបញ្ចប់និទណ្ឌភាពចំពោះបុគ្គលដែលប្រព្រឹត្តអំពើហិង្សាទៅលើអ្នកសារព័ត៌មាន។ ជាពិសេសព្រះរាជអាជ្ញាគួរបើកការស៊ើបអង្កេតឡើងវិញទៅលើអំពើហិង្សាចំនួន ១២ករណី ដែលមានអ្នកសារព័ត៌មាន ១៣ នាក់ត្រូវបានគេសម្លាប់ចាប់តាំងពីការបោះឆ្នោតតាមបែបលទ្ធិប្រជាធិបតេយ្យនៅក្នុងឆ្នាំ១៩៩៣ រហូតមកដល់បច្ចុប្បន្នដែលគេមិនទាន់ឃើញមានការផ្តន្ទាទោសទៅលើករណីទាំងនោះនៅឡើយ។
- ចាងហ្វាងនិងអ្នកបោះពុម្ពផ្សាយសារព័ត៌មានទាំងអស់គួរតែចាត់វិធានការ ដើម្បីធានាឱ្យប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ឬ មិនទទួលរងនូវឥទ្ធិពលនយោបាយ ឬ ផលប្រយោជន៍ធុរកិច្ចណាមួយ។ ប្រព័ន្ធផ្សព្វផ្សាយត្រូវតែធានាឱ្យមានការគោរពក្រមសីលធម៌ និងវិជ្ជាជីវៈរបស់អ្នកសារព័ត៌មានកម្ពុជា។
- ព័ត៌មាននានាគួរតែផ្លាស់ប្តូរទៅរកប្រព័ន្ធផ្សព្វផ្សាយបែបឌីជីថល និងអនឡាញ ទន្ទឹមនឹងមានការកើនឡើង នៃការប្រើប្រាស់អ៊ីនធឺណែតនៅក្នុងប្រទេស ហើយពលរដ្ឋកម្ពុជាបានងាកទៅប្រើប្រាស់ព័ត៌មានតាមរយៈប្រព័ន្ធផ្សព្វផ្សាយតាមអ៊ីនធឺណែត និងសង្គម។
- អង្គការមិនមែនរដ្ឋាភិបាលគួរធ្វើការបំពេញបន្ថែម ទៅលើសេចក្តីសម្រេចរបស់ក្រសួងអប់រំនាពេលថ្មីៗក្នុងការដាក់បញ្ចូលកម្មវិធីអប់រំ ផ្នែកប្រព័ន្ធផ្សព្វផ្សាយទៅក្នុងកម្មវិធីសិក្សាថ្នាក់វិទ្យាល័យ ដើម្បី

ឲ្យយុវជនកម្ពុជាមានជំនាញត្រិះរិះពិចារណាទៅលើភាពខុសគ្នារវាងព័ត៌មាន និងពាក្យចចាមអារាម។

- ក្រសួងព័ត៌មានគួរផ្តល់អាទិភាពក្នុងការបង្កើតច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ដែលនឹងផ្តល់ព័ត៌មានជាសាធារណៈដល់អ្នកសារព័ត៌មាន និងប្រជាពលរដ្ឋទូទៅឲ្យបានស្វែងយល់ពីការពិត និងរាយការណ៍ព័ត៌មានជាក់ស្តែង ដើម្បីផលប្រយោជន៍ប្រជាពលរដ្ឋខ្មែរគ្រប់រូប។ ដូច្នេះរដ្ឋាភិបាលគួរលើកកម្ពស់ឲ្យមានព័ត៌មានសាធារណៈតាមរយៈប្រព័ន្ធអ៊ីនធឺណែតអោយបានច្រើន។
- រដ្ឋសភាគួរធ្វើវិសោធនកម្មលើមាត្រាមួយចំនួនក្នុងក្រមព្រហ្មទណ្ឌដូចជា បទបរិហារកេរ្តិ៍ (មាត្រា៣០៥) បទប្រមាថ (មាត្រា៥០២) ការប្តឹងបរិហារបង្កាច់កេរ្តិ៍ (មាត្រា៣១១) និងបទធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ (មាត្រា៥២៣) ដែលប៉ះពាល់ដល់សេរីភាពខាងការបញ្ចេញមតិ។

លើសពីនេះ យើងខ្ញុំសូមសម្តែងនូវការប្តេជ្ញាចិត្តក្នុងការធ្វើការងារជាមួយភាគីពាក់ព័ន្ធ ទៅលើអ្វីដែលបានលើកឡើងខាងលើ ប្រសិនបើមានឱកាស ដើម្បីសម្រេចគោលដៅទាំងនេះ និងជំរុញឲ្យវិស័យព័ត៌កាន់តែប្រសើរឡើងនៅក្នុងប្រទេសកម្ពុជា។

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ៖*

| | | |
|---|---|---|
| អ្នកស្រី អាម៉ាន់ដា យីង | នាយកផ្នែកទំនាក់ទំនង និងតស៊ូមតិ CCIM | ០៦០ ៤០៣ ៧៧៧ |
| កញ្ញា ឆាយ ឈុនលី | មន្ត្រីសម្របសម្រួលគម្រោង CCHR | ០១៧ ៥២៨ ០២១ |
| អ្នកស្រី ខន សុភី | ប្រធានគម្រោង ACT | ០៩២ ៧៧១ ៤៤៦ |

*ស្ថាប័នដែលបានគាំទ្រសេចក្តីថ្លែងការណ៍នេះ ៖*

១. អង្គការ អាក់សិនអេដកម្ពុជា (ActionAid Cambodia)
អ្នកស្រី ខារ៉ូលីន ម៉ាយលែន៖ នាយកប្រចាំប្រទេស : ០២៣ ៩៩៤ ៩៨៧
២. អង្គការ ក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)
កញ្ញា ស្រី សុធាវី ៖ នាយិកាប្រតិបត្តិ : ០១៧៩៩០ ៣៧១
៣. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
លោក ប៉ា ងួនទៀង៖ នាយកប្រតិបត្តិ : ០៦០ ៤០៩ ៩៩៩
៤. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
អ្នកស្រី ចក់ សុភាព ៖ នាយិកាប្រតិបត្តិ : ០១១ ៩៤៣ ២១៣
៥. គណកម្មការប្រព្រឹត្តិកម្ម នៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)
លោក សួន ប៊ុនសក្តិ៖ លេខាធិការប្រតិបត្តិ : ០៩២ ៣៤៤ ៣៥៧
៦. មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)
លោក យ៉េង វីរៈ ៖ នាយកប្រតិបត្តិ : ០២៣ ២១៥ ៥៩០

៧. អង្គការ ដាយកូនា (Diakonia)

អ្នកស្រី ណេវ៉ា ធួន ៖ នាយកប្រចាំប្រទេស : neva.thiounn@diakonia.se

៨. អង្គការ ក្រុមការងារពិសេសសិទ្ធិលំនៅឋាន (HRT)

លោក សៀ ភារម្យ៖ នាយកប្រតិបត្តិ : ០១២ ៨៥២ ២៦១

៩.សមាគម ផាងត្នោត (STT)

លោក អ៊ី សារ៉ុម ៖ នាយកប្រតិបត្តិ : ០១២ ៨៣៦ ៥៣៣

១០. អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន (Reporters Without Borders)

លោក បេនចេមីន អ៊ីស្មាលះ ប្រធានប្រចាំតំបន់អាស៊ី : asie@rsf.org

១១.អង្គការ តម្លាភាពកម្ពុជា (TI)

លោក ព្រាប កុល ៖ នាយកប្រតិបត្តិ : kolpreap@itcambdodia.org

១២. អង្គការ ជំនួយពួកជំនុំដាណឺម៉ាក/ជំនួយគ្រីស្ទាន (DCA/CA)

បេធី ថូជសេន ៖ នាយកប្រចាំប្រទេស : ០២៣ ២១៦ ២៦១

១៣. សម្ព័ន្ធសារព័ត៌មានអាស៊ីអាគ្នេយ៍ (SEAPA)

លោក អេហ្គាដូ ឡេហ្គាពី ៖ មន្ត្រីទំនាក់ទំនង : epl@seapa.org

១៤. អង្គការ ហ្វ្រីដុមហាសន៍ (Freedom House)

លោក រ៉ូបឺតហរមេន ៖ ប្រធានស្ដីទីគម្រោងប្រចាំតំបន់ : herman@freedomhouse.org